## ៨-១-៣ បុណ្យផ្កា

បុណ្យដែលធ្វើដោយ មានផ្កា ជាសម្ភារៈ ហៅថា បុណ្យផ្កា ដោយគេសន្មតថា ប្រាក់ជាផ្កា យកមកបវារណា ចំពោះព្រះសង្ឃ ដើម្បីសាងអ្វីមួយ ដូចជា កុដិ វិហារ សាលាបុណ្យ សាលារៀន ស្ពាន ស្រះ ជាដើម ដែលជាការ សាងទាំងខាង ពុទ្ធចក្រ ទាំងខាងអាណាចក្រ ជាប្រយោជន៍ ធ្វើឲ្យជាតិ និង សាសនា រុងរឿង។ ដោយការកសាងខ្វះត្រូវចាយ ប្រាក់រាប់ពាន់ រាប់ម៉ឺន ដោយធនធានមានតិច អ្នកមានសទ្ធា មិនអាចសាងម្នាក់ឯងកើត ក៏ផ្តើមជាបុណ្យផ្កាឡើង ដើម្បីអង្គាស ប្រាក់និងបបួលញាតិមិត្តឲ្យចូលរួម ជួយកសាងថាវរៈវត្ថុនោះៗ ។ បុណ្យផ្កាអាចធ្វើបានគ្រប់ពេលវេលាមិនដូចបុណ្យកឋិនទេ។ អាចធ្វើចាប់ពីព្រឹកទៅ ក៏បាន ឬ ក៏ចាប់ធ្វើពីពេលរសៀល ក៏បាន ។

<u>កាតព្វកិច្ចនៃបុណ្យផ្កា</u>

១- កិច្ច សុំវត្តលោក ហែចូល

២- កិច្ច ផ្សាយដំណឹងបុណ្យផ្កា

៣-កិច្ចនមស្សការព្រះរតនត្រ័យ សមាទានសីល សូត្រព្រះបរិត្ត ទេសនា

៤- កិច្ច ដង្ហែ (ប្រសិនបើមានពិធីដង្ហែ)

៥- កិច្ច សូត្រសុន្ទរកថា

៦-កិច្ចវេរដោយប្រកាសថា “វេរប្រគេនព្រះសង្ឃ” បើធ្វើសាលារៀននៅក្នុង វត្តដែលហែចូល ។

*-បើប្រាក់ចំណូលសម្រាប់ធ្វើសាលារៀន នៅវត្តផ្សេង ពីវត្តហែចូល (ដូចជានៅស្រុកខ្មែរ ជាដើម) នោះគ្រាន់តែប្រកាសប្រាក់ចំណូលបានហើយ ។*

*៧- ប្រគេនបច្ច័យដល់ព្រះសង្ឃ*

*៨-កិច្ចឧទ្ទិសផល (សូត្រ យំកិញ្ចិ... ) ៕*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*